00288264

C22/5/30

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
នៅចំពោះមុខអង្គបុរេជំនុំជម្រះ

| | | |
|---|---|---|
| សំណុំរឿងលេខ | ៖ | ០០២/១៩-០៩-២០០៧-អ.វ.ត.ក/~~ក.ស.ច.ស (អបជ ១៧)~~ |
| កាលបរិច្ឆេទនៃការបញ្ជូន | ៖ | ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៩ |
| ភាគីបញ្ជូន | ៖ | ការិយាល័យសហព្រះរាជអាជ្ញា |
| ភាសាដើម | ៖ | អង់គ្លេស |
| ប្រភេទឯកសារ | ៖ | សាធារណៈ |

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 16 / 03 / 2009
ម៉ោង (Time/Heure): 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Ny

## ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងពាក្យសុំរបស់ អៀង សារី ឲ្យពិនិត្យលើវេជ្ជបណ្ឌិតម្នាក់នៅពេលសវនាការផ្ទាល់មាត់ លើបណ្តឹងឧទ្ធរណ៍របស់គាត់ស្តីពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន

**បញ្ជូនដោយ៖**

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Robert PETIT

លោក យ៉េត ចរិយា

លោក William SMITH

លោក តាន់ សេណារ៉ុង

លោក Anees AHMED

**ចែកចាយជូន៖**

**អង្គបុរេជំនុំជម្រះ៖**

ចៅក្រម ប្រាក់ គីមសាន, ប្រធាន

ចៅក្រម Rowan DOWNING

ចៅក្រម ន៍យ ថុល

ចៅក្រម Katinka LAHUIS

ចៅក្រម ហួត វុទ្ធី

**មេធាវីការពារក្តីរបស់ដើមបណ្តឹងឧទ្ធរណ៍/ជនត្រូវចោទឈ្មោះ អៀង សារី៖**

លោក អាង ឧត្តម

លោក Michael G. KARNAVAS

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 17 / 03 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Ny

## ១. សេចក្ដីផ្ដើម

១. នៅក្នុងពាក្យសុំលើកទីពីរ ("ពាក្យសុំលើកទីពីរ") របស់ខ្លួន ដែលបានដាក់នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០០៩ ដើមបណ្ដឹងឧទ្ធរណ៍ស្នើឲ្យអង្គបុរេជំនុំជម្រះ កោះហៅវេជ្ជបណ្ឌិតម្នាក់ឈ្មោះ Paulus Falke ដើម្បីផ្ដល់ភស្តុតាងតាមរយៈប្រព័ន្ធវីដេអូ ក្នុងឋានៈជាអ្នកជំនាញផ្នែកវេជ្ជសាស្ត្រជាអ្នកប្រកបមុខវិជ្ជាពេទ្យទូទៅម្នាក់ ដោយមានមូលដ្ឋាននៅលើសេចក្ដីសង្ខេបមួយ ("សេចក្ដីសង្ខេប") ដែលធ្វើឡើងដោយឯកឯង និងយ៉ាងប្រញាប់ប្រញាល់ ដែលត្រូវបានរៀបចំឡើងដោយខ្លួនគាត់អំពីរបាយការណ៍វេជ្ជសាស្ត្រមុនៗរបស់ដើមបណ្ដឹងឧទ្ធរណ៍[1] ។ ពាក្យសុំលើកទីពីរនេះត្រូវបានដាក់ក្នុងរយៈពេលចំនួនមួយខែ គិតពីការច្រានចោលនូវពាក្យសុំលើកទីមួយរបស់ដើមបណ្ដឹងឧទ្ធរណ៍ ("ពាក្យសុំលើកទីមួយ") ស្នើឲ្យកោះហៅវេជ្ជបណ្ឌិត Falke ដដែលនេះឲ្យធ្វើជា "សាក្សី" ("ដីកាសម្រេចច្រានចោលលើកទីមួយ")[2] ។ ពាក្យសុំលើកទីពីរនេះក៏ត្រូវបានដាក់ក្នុងអំឡុងពេលតែប៉ុន្មានសប្ដាហ៍ប៉ុណ្ណោះ បន្ទាប់ពីការច្រានចោលនូវសំណើដែលមានលក្ខណៈចម្រុះរបស់ដើមបណ្ដឹងឧទ្ធរណ៍ ("សំណើចម្រុះ") ដែលគាត់បានស្វែងរកធ្វើការកោះហៅ៖ (ទី១) <u>គ្រប់</u>វេជ្ជបណ្ឌិត<u>ទាំងអស់</u>ពីមន្ទីរពេទ្យកាល់ម៉ែត ដែលធ្លាប់បានពិនិត្យគាត់ក្នុងរយៈកាលដប់ប្រាំ (១៥) ខែចុងក្រោយនៃការឃុំខ្លួន ។ (ទី២) វេជ្ជបណ្ឌិតដែលប្រចាំការនៅ អ.វ.ត.ក និង (ទី៣) វេជ្ជបណ្ឌិត LAFONT និងវេជ្ជបណ្ឌិត លើវ ឈិញ ដែលធ្លាប់បានពិនិត្យដើមបណ្ដឹងឧទ្ធរណ៍ នៅរយៈពេលប៉ុន្មានខែកន្លងទៅនេះ[3] ។

---

[1] *ករណីរបស់ អៀង សារី,* សំណើជាបន្ទាន់របស់លោក អៀង សារី សុំឲ្យលោកវេជ្ជបណ្ឌិត Paulus Falke ផ្ដល់ភស្តុតាងកោសលវិច័យ នៅក្នុងអំឡុងពេលសវនាការផ្ទាល់មាត់ ស្ដីពីការឃុំខ្លួនផ្ទាល់មាត់នៅថ្ងៃទី២ ខែមេសា ឆ្នាំ២០០៩, ចុះថ្ងៃទី ១២ មីនា ២០០៩ [*ចាប់ពីនេះតទៅហៅថា* ពាក្យសុំលើកទីពីរ] ។

[2] *ករណីរបស់ អៀង សារី,* សេចក្ដីសម្រេចជាលាយលក្ខណ៍អក្សរនៃសេចក្ដីសម្រេចដោយផ្ទាល់មាត់ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៩ លើសំណើដែលបានដាក់ជូននៅចំពោះមុខអង្គបុរេជំនុំជម្រះក្នុងពេលសវនាការ, ចុះថ្ងៃទី២៧ កុម្ភៈ ២០០៩, C22/5/24, ERN 00285102-00285104 [*ចាប់ពីនេះតទៅហៅថា* ដីកាសម្រេចច្រានចោលលើកទីមួយ] ។

[3] *ករណីរបស់ អៀង សារី,* សំណើរបស់លោក អៀង សារី សុំឲ្យកោះអញ្ជើញអ្នកឯកទេសវេជ្ជសាស្ត្រដើម្បីផ្ដល់ភស្តុតាងនាពេលសវនាការដេញដោលផ្ទាល់មាត់ស្ដីពីការឃុំខ្លួនបណ្ដោះអាសន្ន, ចុះថ្ងៃទី៩ កុម្ភៈ ២០០៩, C22/5/11, ERN 00279185-00279190, [*ចាប់ពីនេះតទៅហៅថា* សំណើចម្រុះ] ។ *ករណីរបស់ អៀង សារី,* សេចក្ដីសម្រេចលើសំណើរបស់លោក អៀង សារី សុំឲ្យកោះ

២. សហព្រះរាជអាជ្ញា ស្នើឱ្យ អង្គបុរេជំនុំជម្រះ ច្រានចោលនូវពាក្យសុំលើកទីពីរនេះ ដោយហេតុថា ក្នុងចំណោមហេតុផលទាំងឡាយនោះមាន៖ ទី១) ដើមបណ្ដឹងឧទ្ធរណ៍មិនបានដាក់ឯកសារថ្មីណាមួយ ឬមិនបានលើកបង្ហាញនូវកាលៈទេសៈផ្លាស់ប្ដូរដ៏សំខាន់ណាមួយសម្រាប់ឱ្យ អង្គបុរេជំនុំជម្រះធ្វើការពិចារណាឡើងវិញលើដីកាសម្រេចច្រានចោលលើកទីមួយ របស់ខ្លួននោះឡើយ ។ ទី២) ទោះបីជាអង្គបុរេជំនុំជម្រះ ទទួលយកនូវពាក្យសុំលើកទីពីរនោះក៏ ពាក្យសុំលើកទីពីរ មិនស្របទៅតាមលក្ខខណ្ឌតម្រូវនៃបទប្បញ្ញត្តិច្បាប់ដែលជាទីសំអាងក្នុងការដាក់ពាក្យសុំនោះឡើយ ។ ទី៣) វេជ្ជបណ្ឌិត Falke មិនមានគុណវុឌ្ឍិជាអ្នកជំនាញទេ ។ (ទី៤) ទោះបីជា វេជ្ជបណ្ឌិត Falke សមនឹងទទួលបានថាជាអ្នកជំនាញក៏ដោយក៏ របាយការណ៍សង្ខេបរបស់គាត់មិនមានគុណវុឌ្ឍិជារបាយការណ៍ជំនាញដែរ និងទី៥) ពាក្យសុំលើកទីពីរនេះគឺមានលក្ខណៈខ្ជះខ្ជាយ និងធ្វើឱ្យអន្តរាយដល់សេដ្ឋកិច្ចតុលាការថែមទៀតផង ។

## ២. សេចក្ដីសំអាង

### *ពាក្យសុំមិនត្រូវទៅតាមលក្ខណៈវិនិច្ឆ័យសម្រាប់ការពិចារណាឱ្យមានសេចក្ដីសម្រេចឡើងវិញ*

៣. ដោយមានការលើកឡើងនូវករណីយុត្តិសាស្ត្រ នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ("ICTY") អង្គបុរេជំនុំជម្រះ បានសម្រេចថាខ្លួនអាចពិចារណាលើសេចក្ដីសម្រេចរបស់ខ្លួនឡើងវិញថាតើ៖ ក) កាលៈទេសៈផ្លាស់ប្ដូរណាមួយដែរឬទេ ។ ខ) សេចក្ដីសម្រេចលើកមុនខុស ឬក៏ គ) វាបណ្ដាលឱ្យមានអយុត្តិធម៌[4] ។ ដើមបណ្ដឹងឧទ្ធរណ៍

---

អញ្ជើញអ្នកឯកទេសវេជ្ជសាស្ត្រដើម្បីផ្ដល់ភស្តុតាងនាពេលសវនាការវេញដោយផ្ទាល់មាត់ស្ដីពីការឃុំខ្លួនបណ្ដោះអាសន្ន, ចុះថ្ងៃទី២៣ កុម្ភៈ ២០០៩, C22/5/18, ERN 00282884-00282888 ។

[4] *ករណីរបស់ អៀង សារី*, សេចក្ដីសម្រេចលើពាក្យសុំពិចារណាសារជាថ្មីអំពីសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងការថ្លែងប្រាស្រ័យជូនអង្គបុរេជំនុំជម្រះ ដោយខ្លួនឯង, ចុះថ្ងៃទី២៨ សីហា ២០០៨, C22/1//68, ERN 00221475-00221484, កថាខណ្ឌទី ២៥ [*ចាប់ពីនេះតទៅ ហៅថា* សេចក្ដីសម្រេចលើពាក្យសុំរបស់ សេង ធារី] ដែលលើកឡើងអំពី *រដ្ឋអាជ្ញា ទល់នឹង Garlic*, សេចក្ដីសម្រេចលើពាក្យសុំរបស់អយ្យការស្នើសុំប្ដឹងឧទ្ធរណ៍, សំណុំរឿងលេខ IT-98-29-AR73, លាលាឧទ្ធរណ៍ ICTY, ចុះថ្ងៃទី១៤ ធ្នូ ២០០៦, កថាខណ្ឌទី ១៣ ។

មិនបានបង្ហាញថា លក្ខខណ្ឌណាមួយក្នុងចំណោមលក្ខខណ្ឌទាំងនេះ សមស្របទៅនឹងពាក្យសុំលើកទីពីរ នេះទេ ។

### i) <u>មិនមានកាលៈទេសៈផ្លាស់ប្តូរណាមួយនោះទេ</u>

៤. ដើម្បីឱ្យពាក្យសុំមួយបានទទួលជោគជ័យដោយឈរនៅលើការផ្លាស់ប្តូរកាលៈទេសៈ ទី១) ត្រូវតែមានអង្គហេតុថ្មី ។ ទី២) អង្គហេតុថ្មីនោះត្រូវតែ មិនត្រូវបានដឹងដោយភាគីដែលដាក់ពាក្យសុំ នៅពេលចាប់ផ្តើមដំបូងនៃដំណើរការនីតិវិធី ។ ទី៣) កង្វះខាតនូវការស្រាវជ្រាវអង្គហេតុ ត្រូវតែមិនបណ្តាលមកពីកង្វះខាតនៃការយកចិត្តទុកដាក់ហ្មត់ចត់នៃភាគីដែលដាក់ពាក្យសុំ និងទី៤) គេត្រូវតែបង្ហាញថា អង្គហេតុថ្មីនោះអាចជាកត្តាដាច់ខាត ក្នុងការឈានទៅដល់សេចក្តីសម្រេចពីដំបូង[5] ។

៥. ដីកាសម្រេចច្រានចោលលើកទីមួយ បានបដិសេធលើពាក្យសុំលើកទីមួយរបស់ ដើមបណ្តឹងឧទ្ធរណ៍ ដែលសុំឱ្យគេ "អនុញ្ញាតឱ្យវេជ្ជបណ្ឌិត Falke ផ្តល់នូវភស្តុតាង នៅពេលសវនាការផ្ទាល់មាត់"[6] ។ ដើមបណ្តឹងឧទ្ធរណ៍ មិនបានលើកឡើងនូវការផ្លាស់ប្តូរកាលៈទេសៈដ៏សំខាន់ណាមួយ ដែលជាការចាំបាច់សម្រាប់ឱ្យមានការពិចារណាឡើងវិញលើដីកាសម្រេចច្រានចោលលើកទីមួយ ។ ដើមបណ្តឹងឧទ្ធរណ៍ ក៏មិនបានលើកឡើងថា ដីកាសម្រេចច្រានចោលលើកទីមួយមានកំហុសឆ្គង ឬបណ្តាលឱ្យមានអយុត្តិធម៌ទេ ។ ពាក្យសុំលើកទីមួយ ត្រូវបានច្រានចោលនូវការលើកឡើងរបស់ដើមបណ្តឹងឧទ្ធរណ៍ ដែលថាវេជ្ជបណ្ឌិត Falke ត្រូវបានស្វែងរកឱ្យមានការកោះហៅធ្វើជា "សាក្សីម្នាក់ និងមិនមែន [...] ជាអ្នកជំនាញម្នាក់

[5] *រដ្ឋអាជ្ញា ទល់នឹង Barayagwiza,* សេចក្តីសម្រេចលើសំណើរបស់អយ្យការសុំឱ្យពិនិត្យ ឬពិចារណាឡើងវិញ, សំណុំរឿងលេខ ICTR-97-19-AR72, លាលាឧទ្ធរណ៍ ICTR, ចុះថ្ងៃទី៣១ មីនា ២០០០, កថាខណ្ឌទី ៥១ ។

[6] *ករណីរបស់ អៀង សារី,* សំណើរបស់លោក អៀង សារី សុំឱ្យដាក់បញ្ចូលបន្ថែមនូវរបាយការណ៍វេជ្ជសាស្ត្ររបស់វេជ្ជបណ្ឌិត Paulus Falke ទៅក្នុងសំណុំរឿង និងសំណើសុំអនុញ្ញាតឱ្យវេជ្ជបណ្ឌិត Paulus Falke ដើម្បីផ្តល់ភស្តុតាងតាមរយៈការផ្សាយបន្តផ្ទាល់តាមរូបភាពវីដេអូ (videolink) នាពេលសវនាការថ្ងៃទី២៦ កុម្ភៈ ២០០៩, ចុះថ្ងៃទី២០ កុម្ភៈ មីនា ២០០៩, C22/5/16, ERN 00283206-00283208 [*ចាប់ពីនេះតទៅហៅថា* ពាក្យសុំលើកទីមួយ] ។

00288268



នោះទេ"[7] ។ នៅក្នុងពាក្យសុំលើកទីពីរ ដើមបណ្តឹងឧទ្ធរណ៍ បានពឹងផ្អែកលើឯកសារដូចគ្នា ដែលធ្លាប់បានដាក់នៅក្នុងពាក្យសុំលើកទីមួយ ។ ការល្អប្រសើរឡើងមានតែមួយគត់នៅក្នុង ពាក្យសុំលើកទីពីរ - មិនមានសារៈសំខាន់អ្វី - គឺថាពាក្យសុំលើកទីពីរ បានស្វែងរកឱ្យមានការ កោះហៅវេជ្ជបណ្ឌិត Falke ឱ្យធ្វើជាអ្នកជំនាញម្នាក់ផ្នែកវេជ្ជសាស្ត្រ[8] ។

៦. ដោយសង្ខេបទៅ ដើមបណ្តឹងឧទ្ធរណ៍ មិនបានចោទប្រកាន់ថាមានការបង្ហាញតិចតួចអំពីការ ផ្លាស់ប្តូរកាលៈទេសៈសំខាន់ណាមួយឡើយ ដែលតម្រូវឱ្យមានការពិចារណាឡើងវិញអំពី ដីកាសម្រេចច្រានចោលលើកទីមួយ របស់អង្គបុរេជំនុំជម្រះនោះឡើយ ។ ហេតុដូច្នេះ ការពិចារណាឡើងវិញ មិនត្រូវបានអនុញ្ញាតឱ្យមាននោះឡើយ ។

## ii) ដីកាសម្រេចច្រានចោលលើកទីមួយ មិនខុសទេ

៧. តាមផ្លូវតុលាការ អំណាចក្នុងពិចារណាសេចក្តីសម្រេចអ្វីមួយឡើងវិញ គឺមានលក្ខណៈជាការ សម្រេចចិត្ត (discretionary) ។ នៅក្នុងកាលៈទេសៈពិសេស សេចក្តីសម្រេចមួយអាចត្រូវ បានពិចារណាឡើងវិញ បើ "ការពិចារណាមានហេតុផលច្បាស់លាស់អំពីកំហុសឆ្គង ត្រូវបាន លាតត្រដាង"[9] ។ ដើមបណ្តឹងឧទ្ធរណ៍ មិនបានបង្ហាញអំពីវត្តមាននៃកាលៈទេសៈពិសេស ចាំបាច់ដែលតម្រូវឱ្យមានការប្រើប្រាស់នូវសេរីភាពក្នុងការសម្រេច (discretion) នោះទេ ។ ដើមបណ្តឹងឧទ្ធរណ៍ ថែមទាំងមិនបានរៀបចំបង្ហាញអំពី "កំហុសឆ្គងដ៏ច្បាស់លាស់" ណាមួយ ទៅលើដីកាសម្រេចច្រានចោលលើកទីមួយ របស់អង្គបុរេជំនុំជម្រះដែរ ។

## iii) ដើមបណ្តឹងឧទ្ធរណ៍ មិនបានបង្ហាញថា ដីកាសម្រេចច្រានចោលលើកទីមួយ បណ្តាលឱ្យមានអយុត្តិធម៌ នោះទេ

---

[7] ដីកាសម្រេចច្រានចោលលើកទីមួយ, កថាខណ្ឌទី ២ ។

[8] ពាក្យសុំលើកទីពីរ, កថាខណ្ឌទី ៥ ។

[9] សេចក្តីសម្រេចលើពាក្យសុំរបស់ សេង ធារី, កថាខណ្ឌទី ២៥ ។

៨. ដើមបណ្ដឹងឧទ្ធរណ៍ មិនបានបង្ហាញថា ដីកាសម្រេចច្រានចោលលើកទីមួយបណ្ដាលឱ្យមានអយុត្តិធម៌ទេ ឬមួយក៏ថា បើសេចក្ដីសម្រេចនោះមិនត្រូវបានពិចារណាឡើងវិញ ខ្លួននឹងទទួលរងនូវការខាតបង់ដែលមិនអាចជួសជុលបាន និងបុរេវិនិច្ឆ័យនោះដែរ ។ ហេតុដូច្នេះ សហព្រះរាជអាជ្ញា សន្និដ្ឋានថា ការពិចារណាឡើងវិញអំពីដីកាសម្រេចច្រានចោលលើកទីមួយរបស់អង្គបុរេជំនុំជម្រះ មិនត្រូវអនុញ្ញាតឱ្យទេ ។

## *ពាក្យសុំមិនត្រូវទៅតាមលក្ខខណ្ឌតម្រូវនៃបទប្បញ្ញត្តិច្បាប់ ដែលជាទីសំអាងក្នុងការដាក់ពាក្យសុំនោះឡើយ*

៩. ពាក្យសុំលើកទីពីរ ត្រូវបានដាក់ដោយបានអះអាងទៅលើវិធាន ៣១ ឱ្យចាត់ទុកវេជ្ជបណ្ឌិត Falke ថាជា "អ្នកជំនាញ" ម្នាក់ ។ ពាក្យសុំនេះ បើដូចដែលបានដាក់បង្ហាញដូច្នេះ នោះវាគឺមានការកាត់យល់ខុសហើយ (misconceived) ។

១០. វិធាន ៣១ បានចែងអំពីសកម្មភាពមួយចំនួនដែលត្រូវបំពេញ មុននឹងជនណាម្នាក់ត្រូវបានតែងតាំងឱ្យធ្វើជា "អ្នកជំនាញ" ហើយនិងជំនាញរបស់គាត់ត្រូវបានទទួលយកដោយអង្គជំនុំជម្រះនេះ ។ ឧទាហរណ៍៖ ក) អ្នកជំនាញ ត្រូវបានតែងតាំងដោយដីកាសម្រេចរបស់អង្គភាពតុលាការដែលពាក់ព័ន្ធនៃអង្គជំនុំជម្រះនេះ[10] ។ ខ) អ្នកជំនាញ ត្រូវបំពេញភារកិច្ចរបស់ខ្លួនក្រោមការឃ្លាំមើលរបស់អង្គភាពតុលាការទាំងនោះ[11] ។ គ) ដីកាតែងតាំងរបស់អ្នកជំនាញ ត្រូវមានចែងឱ្យច្បាស់អំពីភារកិច្ច និងថិរវេលាបំពេញការងារ[12] ។ល។ មិនមានលក្ខខណ្ឌតម្រូវណាមួយក្នុងចំណោមលក្ខខណ្ឌតម្រូវទាំងនេះ ត្រូវបានបំពេញនោះទេនៅក្នុងករណីរបស់វេជ្ជបណ្ឌិត Falke ។ នៅក្នុងពាក្យសុំលើកទីពីរនេះ ក៏មិនច្បាស់លាស់ផងដែរ អំពីថាតើដើមបណ្ដឹងឧទ្ធរណ៍ មានបំណងចង់ដាក់សេចក្ដីសង្ខេបដែលធ្វើឡើងដោយវេជ្ជបណ្ឌិត Falke ថាជារបាយការណ៍ជំនាញ ឬមួយក៏ស្វែងរកនូវដីកាសម្រេចតែងតាំង

---

[10] វិធានផ្ទៃក្នុង, វិធាន ៣១.៣ [*ចាប់ពីនេះតទៅហៅថា* វិធាន] ។

[11] វិធាន, វិធាន ៣១.៤ ។

[12] វិធាន, វិធាន ៣១.៣ ។

អ្នកជំនាញពីសំណាក់អង្គបុរេជំនុំជម្រះ ដើម្បីស្វែងរកនូវរបាយការណ៍ជំនាញថ្មីមួយពីវេជ្ជបណ្ឌិត Falke ។

១១. បើតាមការសំអាង បើពាក្យសុំលើកទីពីរនេះ ត្រូវបានពិចារណាថាត្រូវបានដាក់ទៅតាមវិធាន ៣២ នោះជាថ្មីម្តងទៀត ពាក្យសុំនោះមិនបានបំពេញនូវលក្ខណៈវិនិច្ឆ័យដែលបានតម្រូវទេ ។ ឧទាហរណ៍ តាមវិធាន ៣២ អ្នកជំនាញដែលធ្វើការពិនិត្យផ្នែកវេជ្ជសាស្ត្រដល់ចុងចោទ៖ ក) អាចត្រូវបានតែងតាំងដោយអង្គភាពតុលាការណាមួយនៃអង្គជំនុំជម្រះនេះតែប៉ុណ្ណោះ ។ ខ) ការតែងតាំងត្រូវតែស្របទៅតាមសេចក្តីបង្គាប់ដែលមានមូលហេតុត្រឹមត្រូវ ។ គ) អ្នកជំនាញ ត្រូវផ្តល់ជូននូវរបាយការណ៍ <u>បន្ទាប់ពី</u> ចុងចោទបានទទួលនូវ "ការត្រួតពិនិត្យផ្នែកវេជ្ជសាស្ត្រ វិកលចរិក ឬ ចិត្តសាស្ត្រ" ដោយអ្នកជំនាញ ។ មិនមានលក្ខខណ្ឌតម្រូវណាមួយក្នុងចំណោមលក្ខខណ្ឌតម្រូវទាំងនេះ ត្រូវបានបំពេញនោះទេ នៅក្នុងករណីរបស់វេជ្ជបណ្ឌិត Falke ។

១២. ហេតុដូច្នេះ សហព្រះរាជអាជ្ញា ស្នើឱ្យ អង្គបុរេជំនុំជម្រះ បដិសេធពាក្យសុំលើកទីពីរនេះចោល ដោយហេតុថា ពាក្យសុំនេះគឺមានលក្ខណៈកាត់យល់ខុស (misconceived) ទៅតាមផ្លូវច្បាប់ ។

## *វេជ្ជបណ្ឌិត Falke មិនមានគុណវុឌ្ឍិជា "អ្នកជំនាញ" នៅក្នុងដំណើរការនីតិវិធីនេះទេ*

១៣. យុត្តិសាស្ត្រអន្តរជាតិ តម្រូវឱ្យភាគីដែលកំពុងអំពាវនាវ (calling party) ប្រាកដក្នុងចិត្តថាជំនាញដែលបានស្នើឡើងមាន "ចំណេះដឹង បទពិសោធន៍ ឬជំនាញចាំបាច់ពិសេសៗ ដែលអាចប្រើប្រាស់តាមចិត្តរបស់ខ្លួន ដើម្បីជួយឱ្យបានជាសក្តានុពលដល់ [អង្គជំនុំជម្រះតុលាការ] ក្នុងការយល់ដឹង ឬក្នុងការធ្វើសេចក្តីសម្រេច" លើបញ្ហាដែលកំពុងតវ៉ា[13] ។ សក្ខីកម្មរបស់

[13] *ព្រះរាជអាជ្ញា ទល់នឹង Milutinovic និងគូកន,* សេចក្តីសម្រេចលើកស្ទួតាងដែលបានស្នើប្រគល់ជូនជាផ្លូវការដោយវេជ្ជបណ្ឌិត Eric Baccard, សំណុំរឿងលេខ: IT-05-87-T, ចុះថ្ងៃទី១៦ មីនា ២០០៧, កថាខណ្ឌទី១៣ ។

អ្នកជំនាញ គឺមានគោលបំណងដើម្បីជួយបំភ្លឺដល់អង្គជំនុំជម្រះតុលាការ អំពីបញ្ហាបច្ចេកទេសជាក់លាក់មួយចំនួន ដែលទាមទារនូវចំណេះដឹងពិសេស នៅក្នុងផ្នែកជាក់លាក់នោះ[14] ។ ភាពខុសគ្នាមួយក្នុងចំណោមភាពខុសគ្នាទាំងឡាយរវាងសាក្សីជំនាញ និងសាក្សីអង្គហេតុ (fact witness) គឺថា ដោយសារគុណវុឌ្ឍិនៃអ្នកជំនាញដែលខ្លួន អាចផ្តល់នូវមតិយោបល់ និងសេចក្តីសន្និដ្ឋានផ្សេងៗ ព្រមទាំងអាចបង្ហាញមតិ និងសេចក្តីសន្និដ្ឋានទាំងនោះ ជូនអង្គជំនុំជម្រះបាន[15] ។

១៤. ជំនាញរបស់វេជ្ជបណ្ឌិត Falke ប្រសិនបើមាន ក៏មិនសមស្របនៅក្នុងកិច្ចដំណើរការនីតិវិធីនាពេលបច្ចុប្បន្ននេះដែរក្នុងគោលបំណងដើម្បីកោះហៅរូបគាត់ ជាពិសេស៖

i. វេជ្ជបណ្ឌិត Falke មិនធ្លាប់ជួបដើមបណ្តឹងឧទ្ធរណ៍ទេ ហើយក៏មិនធ្លាប់មកធ្វើទស្សនកិច្ចនៅមន្ទីរឃុំឃាំង អ.វ.ត.ក ដែរ ។

ii. វេជ្ជបណ្ឌិត Falke មិនធ្លាប់ជួប ហើយក៏មិនធ្លាប់បាននិយាយជាមួយអ្នកជំនាញណាមួយដែលធ្លាប់បានពិនិត្យដើមបណ្តឹងឧទ្ធរណ៍ទេ ។ ជាពិសេស គាត់មិនធ្លាប់ជួបជាមួយវេជ្ជបណ្ឌិតប្រចាំការនៅមន្ទីរឃុំឃាំងអ.វ.ត.ក ដែលជាអ្នកបានពិនិត្យដើមបណ្តឹងឧទ្ធរណ៍យ៉ាងទៀងទាត់ស្ទើរតែជាប្រចាំថ្ងៃនោះទេ តាំងពីពេលចាប់ខ្លួនគាត់មក ។ វេជ្ជបណ្ឌិត Falke មិនធ្លាប់បានឃើញរបាយការណ៍វេជ្ជសាស្ត្រប្រចាំថ្ងៃ ដែលត្រូវបានរាយការណ៍ថាបានរក្សាទុកដោយវេជ្ជបណ្ឌិតប្រចាំការនៅមន្ទីរឃុំឃាំង អ.វ.ត.ក ទេ ។

iii. វេជ្ជបណ្ឌិត Falke ជាអ្នកប្រកបវិជ្ជាជីវៈទូទៅម្នាក់ចំណែកជម្ងឺដែលទទួលរងការឈឺចាប់ដោយដើមបណ្តឹងឧទ្ធរណ៍តម្រូវឱ្យមានអ្នកជំនាញពិសេស ដូចជាគ្រូពេទ្យខាងបេះដូង គ្រូពេទ្យខាងតម្រងនោមជាដើម ។ល។ ភាគច្រើននៃអ្នកជំនាញទាំងនេះ ទាំងគ្រូពេទ្យខ្មែរ

---

[14] *រដ្ឋអាជ្ញា ទល់នឹង Norman និងគូកន*, សេចក្តីសម្រេចលើពាក្យសុំរបស់ Fofana ដែលបានស្នើឱ្យកោះហៅសាក្សីបន្ថែម, សំណុំរឿងលេខ: SCSL-04-14-T, ចុះថ្ងៃទី១៧ កក្កដា ២០០៦, ទំព័រទី៤ ។

[15] *រដ្ឋអាជ្ញា ទល់នឹង Blagojevic និងគូកន*, សេចក្តីសម្រេចលើញត្តិស្នើសុំការចោទប្រកាន់ ឱ្យទទួលយកសេចក្តីថ្លែងការណ៍របស់អ្នកជំនាញ, សំណុំរឿងលេខ: IT-02-60-T, ចុះថ្ងៃទី៧ វិច្ឆិកា ២០០៣, កថាខ័ណ្ឌទី១៩ ។

និងអន្តរជាតិ ធ្លាប់បានប្រគល់ជូនជាផ្លូវការរួចមកហើយ នូវរបាយការណ៍ពិស្តាររបស់អ្នកជំនាញដែលមាននៅក្នុងសំណុំរឿង ។

iv. វេជ្ជបណ្ឌិត Falke មិនមែនជាចិត្តវិទូ គ្រូពេទ្យជំនាញខាងមនុស្សចាស់ ឬគ្រូពេទ្យខាងចិត្តសាស្ត្រនៃតុលាការ ដែលធ្វើឱ្យគាត់មានគុណវុឌ្ឍិក្នុងការផ្តល់មតិយោបល់អំពី (១) សម្បទាសមស្របរបស់ដើមបណ្តឹងឧទ្ធរណ៍ ដើម្បីចូលរួមនៅក្នុងសវនាការ ឬ (២) ការចូលរួមរបស់គាត់នៅក្នុងកិច្ចការការពារផ្ទាល់ខ្លួនគាត់ឡើយ ។ ទាំងអស់នេះ គឺជាកិច្ចការដែលវេជ្ជបណ្ឌិតបានស្វែងរកដើម្បីផ្តល់មតិយោបល់នៅលើរបាយការណ៍របស់គាត់[16] ។ គាត់មិនសមស្របជាអ្នកជំនាញ ដើម្បីកំណត់អំពីកិច្ចការទាំងអស់នេះទេ ទាក់ទងនឹងច្បាប់ដែលមានចែងនៅក្នុងសេចក្តីសម្រេចរបស់ ICTY ក្នុងករណី *Strugar* និង នៅក្នុងសេចក្តីសម្រេចរបស់អង្គចៅក្រមពិសេសសម្រាប់ទីម័រខាងកើត ក្នុងករណី *Nahak* ឡើយ ។ ករណីទាំងនេះ ត្រូវបានលើកយោងដោយមានការអនុម័តយល់ព្រមដោយ អង្គបុរេជំនុំជម្រះ ក្នុងពេលធ្វើការបដិសេធលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងឧទ្ធរណ៍ ទាក់ទងនឹងការចាត់តាំងអ្នកជំនាញផ្នែកចិត្តសាស្ត្រម្នាក់ ដើម្បីវាយតម្លៃអំពីសម្បទាក្នុងការចូលរួមសវនាការ[17] ។ នៅក្នុងសេចក្តីសម្រេចនោះចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះបានធ្វើការវិភាគលើភស្តុតាងវេជ្ជសាស្ត្រដែលមានស្រាប់ ដើម្បីសម្រេចថា "គ្មានរបាយការណ៍ផ្នែកវេជ្ជសាស្ត្រ ឬរបាយការណ៍របស់អ្នកជំនាញណាមួយបញ្ជាក់ថា ជម្ងឺដែល [ដើមបណ្តឹងឧទ្ធរណ៍] កំពុងតែទទួលរងការឈឺចាប់នោះ មានអនុភាពទៅលើសមត្ថភាពផ្លូវចិត្តរបស់គាត់ឡើយ"[18] ។ ដើមបណ្តឹងឧទ្ធរណ៍ បានលើកយោងដោយគ្មានបង្ហាញពីការផ្លាស់ប្តូរជាក់ស្តែងអំពីកាលៈទេសៈឡើយ ដែលជាការចាំបាច់ឱ្យមាន

[16] សំណើលើកទីមួយ, ឧបសម្ព័ន្ធ ខ, របាយការណ៍របស់វេជ្ជបណ្ឌិត Paulus Falke, ទំព័រទី១ ។

[17] *ករណីរបស់ អៀង សារី,* សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ទាក់ទងនឹងការចាត់តាំងអ្នកជំនាញផ្នែកចិត្តសាស្ត្រ, ចុះថ្ងៃទី ២១ ខែតុលា ឆ្នាំ២០០៨, A189/I/8, ERN 00233433-00233443, កថាខ័ណ្ឌទី៣៩, ៤០, ៤៦ [*ចាប់ពីនេះតទៅហៅថា* សាលដីការបស់ អ.ប.ជ លើអ្នកជំនាញផ្នែកចិត្តសាស្ត្រ] ។

[18] សាលដីការបស់ អ.ប.ជ លើអ្នកជំនាញផ្នែកចិត្តសាស្ត្រ, កថាខ័ណ្ឌទី៤៣ ។ ភាគច្រើនបំផុតនៃរបាយការណ៍របស់អ្នកជំនាញ និងរបាយការណ៍វេជ្ជសាស្ត្រដែលបានលើកយោងនៅក្នុងសាលដីកានេះ ក៏បានប្រើប្រាស់ដោយវេជ្ជបណ្ឌិត Falke ដើម្បីចេញនូវសេចក្តីសង្ខេបរបស់គាត់ផងដែរ ។

ការពិចារណាឡើងវិញលើសេចក្ដីសម្រេចដោយអង្គជំនុំជម្រះនោះ និងដើម្បីស្វែងរកអ្នកជំនាញខាងចិត្តសាស្ត្រផ្នែកនីតិវេជ្ជវិទ្យា (forensic psychiatrist) ដែលមានគុណវុឌ្ឍិពិតប្រាកដ (គឺជាជំនាញដែលវេជ្ជបណ្ឌិត Falke មិនមាន) ។

v. "សម្បទាប្លែកពិសេស" ដែលបានលើកយោងទាក់ទងនឹងជំនាញរបស់លោក Falke គឺចំណុចដែលថា គាត់គឺជាវេជ្ជបណ្ឌិតរបស់អង្គភាពនៅមន្ទីរឃុំឃាំង ICTY[19] ។ នេះគឺជាគុណវុឌ្ឍិមិនមានលក្ខណៈពិសេសអ្វីឡើយទៅនឹងបរិបទបច្ចុប្បន្ន ហើយការពិត ក៏មិនមែនធ្វើឱ្យគាត់ពិសេសប្លែកពីគេដែរ ។ ដោយគ្រាន់តែជាអ្នកប្រកបវិជ្ជាជីវៈទូទៅម្នាក់ នៅអង្គភាពមន្ទីរឃុំឃាំងនៅប្រទេសអឺរ៉ុបមួយ ដែលធ្វើការសំខាន់ជាមួយអ្នកជាប់ឃុំឃាំងអឺរ៉ុប ដែលពួកគេមានទម្លាប់នៃការបរិភោគអាហារ របៀបរស់នៅ ជម្ងឺ ចិត្តសាស្ត្រជាក់លាក់ ។ល។ នោះមិនមែនមានន័យថា វេជ្ជបណ្ឌិត Falke មានគុណវុឌ្ឍិពិសេស ក្នុងការផ្ដល់មតិយោបល់ពីកន្លែងដាច់ស្រយ៉ាលនៅលើបញ្ហាដ៏ទូលំទូលាយ ដែលមេធាវីការពារក្ដីបានដាក់ជូនគាត់ឡើយ ។ គ្មានការប្រាប់ឱ្យដឹងដែលថា វេជ្ជបណ្ឌិត Falke មានជំនាញជាក់លាក់ណាមួយអំពីឱសថក្នុងតំបន់ត្រូពិក ឬថាគាត់ដឹងពីទម្លាប់នៃការបរិភោគអាហាររបៀបរស់នៅ ជម្ងឺចិត្តសាស្ត្រជាក់លាក់ ។ល។ របស់អ្នកជម្ងឺនៅកម្ពុជាដែរ ។

vi. តាមប្រវត្តិរូបការងាររបស់វេជ្ជបណ្ឌិត Falke គឺមានមានលក្ខណៈជាស្វ័យប្រកាស ក្នុងទម្រង់មួយ "ខ្លី" ហើយគាត់ក៏មិនបានបញ្ជាក់ឱ្យឃើញពីមូលហេតុ ដែលថាគាត់មានគុណវុឌ្ឍិនោះដែរ កុំថាឡើយដល់ "ភាពពិសេសខុសប្លែកពីគេ" ដែលត្រូវកោះអញ្ជើញដោយអង្គបុរេជំនុំជម្រះតាមកិច្ចដំណើរការនីតិវិធីបច្ចុប្បន្ននេះ[20] ។

១៥. សំណើលើកទីមួយបាននិយាយថា គោលបំណងស្នើឱ្យកោះអញ្ជើញ វេជ្ជបណ្ឌិត Falke គឺដើម្បីឱ្យ "ធ្វើការពន្យល់ឱ្យបានពេញលេញ អំពីពាក្យពេចន៍ខាងផ្នែកវេជ្ជសាស្ត្រដ៏ស្មុគ្រស្មាញដែលមានសរសេរនៅក្នុងរបាយការណ៍ [មុនៗ] និងដើម្បីបំភ្លឺនូវភាពស្រពិចស្រពិលណាមួយ

---

[19] សំណើលើកទីមួយ, ទំព័រទី៨ ។

[20] សំណើលើកទីមួយ, ឧបសម្ព័ន្ធ គ, ប្រវត្តិរូបការងាររបស់វេជ្ជបណ្ឌិត Paulus Falke ។

ដោយសារការបកប្រែ នៃរបាយការណ៍ទាំងនោះឲ្យទៅជាភាសាផ្សេងៗគ្នា”[21] ។ ក៏ប៉ុន្តែក្នុងសំណើទីមួយនេះ មិនបានបង្ហាញឲ្យឃើញអំពីថាតើ លោកវេជ្ជបណ្ឌិត Falke ជាអ្នកមាន “គុណវុឌ្ឍិពិសេសប្លែកពីគេ” ដើម្បីពន្យល់ដោយយ៉ាងដូចម្តេចអំពីពាក្យពេចន៍ខាងវេជ្ជសាស្ត្រដ៏ស្មុគ្រស្មាញនេះ ឬ ដើម្បីដោះស្រាយអំពី “ភាពស្រពិចស្រពិលដោយសារការបកប្រែ” ។ ហេតុដូច្នេះហើយ បានជាសំណើលើកទីមួយនេះ ត្រូវបានបដិសេធយ៉ាងត្រឹមត្រូវដោយអង្គបុរេជំនុំជម្រះ នៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០៩ ។

១៦. ក្នុងពាក្យសុំទី២ ឥឡូវនេះបានស្វែងរកសុំឲ្យចេញដីកាកោះអញ្ជើញ លោកវេជ្ជបណ្ឌិត Falke ឲ្យមកជួយដល់អង្គបុរេជំនុំជម្រះ “ដើម្បីពន្យល់ឲ្យបានយល់អំពីរបាយការណ៍វេជ្ជសាស្ត្រនានារបស់[ដើមបណ្តឹងឧទ្ធរណ៍] អំពីបទដ្ឋានជាអប្បបរមាស្តីពីការព្យាបាលជម្ងឺ និងអំពីការធ្វើតេស្តសាកល្បងដែលមនុស្សដែលមានវ័យនិងសុខភាពដូចជា[ដើមបណ្តឹងឧទ្ធរណ៍] នេះអាចទទ្ទឹងចង់បាន-ហើយដែលនឹងត្រូវមានសិទ្ធិ បើសិនជាត្រូវឃុំខ្លួននៅឯ[អង្គភាពឃុំឃាំងរបស់តុលាការ ICTY] និងអំពីផលប៉ះពាល់ដោយសារការជាប់ឃុំឃាំងដែល មានរយៈពេលយូរចំពោះសុខភាពរបស់[ជនជាប់ឃុំ]”[22]។ សហព្រះរាជអាជ្ញា សូមជូនសេចក្តីសន្និដ្ឋានថា ដើមបណ្តឹងឧទ្ធរណ៍មិនបានផ្តល់មូលហេតុគ្រប់គ្រាន់ទេ នៅក្នុងពាក្យសុំទីពីរ ដែលស្នើឲ្យចេញដីកាកោះអញ្ជើញលោកវេជ្ជបណ្ឌិតFalke នេះ។ ទី១ គឺដោយលោកវេជ្ជបណ្ឌិត Falke គ្មានបានលើកឡើងអំពីបញ្ហាណាមួយក្នុងចំណោមបញ្ហាទាំងនេះទេ នៅក្នុងសេចក្តីសង្ខេបរបស់គាត់ ។ ទី២ គឺក្នុងពេលមួយដ៏ខ្លីមុនពេលត្រូវបើកសវនាការនៅថ្ងៃទី២ ខែមេសា ឆ្នាំ២០០៩ ដូចនេះគាត់ហាក់ដូចជាមិនទំនងជានឹងអាចផ្តល់មតិនៅលើបញ្ហាទាំងនេះបានទេហើយក៏មិនអាចមានពេលវេលាគ្រប់គ្រាន់ដើម្បីឲ្យគាត់ត្រៀមរៀបចំធ្វើជារបាយការណ៍មួយ ដែលអាចអនុញ្ញាតឲ្យគ្រប់ភាគីទាំងអស់ត្រៀមលក្ខណៈសម្រាប់ការពិនិត្យរបស់គាត់បានដែរ។ ទី៣ គឺដូចដែលបានលើកឡើងពីខាងលើរួចហើយ លោកវេជ្ជបណ្ឌិត Falke មិនសមស្របសម្រាប់ឲ្យធ្វើការផ្តល់មតិទៅលើរបាយការណ៍ដែលទទួលបានមកពីអ្នកជំនាញនានា ដែលមានគុណវុឌ្ឍិខ្ពស់ជាងគាត់នោះទេ។ ទី៤ ចំពោះបញ្ហាស្តីពីបទដ្ឋានអន្តរជាតិក្នុងការឃុំខ្លួន ត្រូវបាន

---

[21] សំណើលើកទីមួយ, ទំព័រទី១ ។

[22] ពាក្យសុំទី២ កថាខណ្ឌទី៨។

លើកឡើងដោះស្រាយយ៉ាងគ្រប់គ្រាន់ និងដដែលៗជាបន្តបន្ទាប់រួចហើយ ដោយតុលាការនេះអនុញ្ញាតឲ្យគណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ (ICRC) ចូលមកទស្សនានៅអង្គភាពឃុំឃាំងរបស់ខ្លួន។ នៅក្នុងពេលចូលមកធ្វើទស្សនកិច្ចរបស់ខ្លួននោះអង្គការ ICRC បានធ្វើសម្ភាសន៍អាជ្ញាធរនៃមន្ទីរឃុំឃាំង ត្រួតពិនិត្យមើលបរិវេណទីតាំងនៃមន្ទីរឃុំឃាំង ធ្វើសម្ភាសន៍ជនជាប់ឃុំ និងបុគ្គលិកពេទ្យដែលនៅក្នុងមន្ទីរឃុំឃាំងនេះ[23]។ ទី៥ គឺដូចដែលសហព្រះរាជអាជ្ញា បានលើកឡើងជាទម្លីករណ៍កាលពីមុនរួចមកហើយថា នៅក្នុងបណ្តឹងឧទ្ធរណ៍ជំទាស់នឹងការបន្តចិរវេលានៃការឃុំខ្លួននេះគឺមិនបានលើកឡើងជាក់ស្តែងអំពីបញ្ហាស្តីពីសុខភាពរបស់ដើមបណ្តឹងឧទ្ធរណ៍ទេហើយបញ្ហានេះទៀតសោតក៏មិនត្រូវបានលើកឡើងពិភាក្សាដោយសហចៅក្រមស៊ើបអង្កេតនៅក្នុងដីកាសម្រេចរបស់ខ្លួន ស្តីពីការបន្តចិរវេលានៃការឃុំខ្លួននោះដែរ[24]។

១៧. អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញា សូមស្នើដល់អង្គបុរេជំនុំជម្រះ ឲ្យបដិសេធចោលនូវពាក្យសុំខាងលើ ដោយលោកវេជ្ជបណ្ឌិត Falke មិនសមស្របសម្រាប់ធ្វើការផ្តល់នូវការធ្វើកោសលវិច័យតាមដូចដែលបានស្នើឡើងនៅក្នុងពាក្យសុំនោះទេ។

### *បើសិនជាលោកវេជ្ជបណ្ឌិត Falke ត្រូវបានយល់ឃើញថាជាអ្នកជំនាញឯកទេសមួយរូបនោះ ប្រវត្តិរូបសង្ខេបរបស់គាត់ក៏មិនមានគុណវុឌ្ឍិជាអ្នកឯកទេសខាងរបាយការណ៍បានដែរ*

១៨. ទោះបីជាត្រូវបានសន្មតដោយយោលទៅតាមការលើកឡើងនូវសំអាងដែលថា លោកវេជ្ជបណ្ឌិត Falke អាចមានគុណវុឌ្ឍិជាអ្នកជំនាញឯកទេសមួយរូបបាន អនុលោមតាមវិធាន៣១

---

[23] *ករណីរឿងរបស់ អៀង សារី,* លិខិតរបស់អង្គការ ICRC ផ្ញើជូនលោកប្រធានរដ្ឋបាលនៃ អ.វ.ត.ក ចុះថ្ងៃទី១១ ខែមករា ២០០៨, ឯកសារលេខ A57, ERN 00158321។

[24] *ករណីរឿងរបស់ អៀង សារី,* ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ អៀង សារី ដែលស្នើសុំឲ្យពិនិត្យអ្នកជំនាញវេជ្ជសាស្ត្រនៅក្នុងពេលសវនាការផ្ទាល់មាត់លើបណ្តឹងឧទ្ធរណ៍ស្តីពីការបន្តចិរវេលានៃការឃុំខ្លួន ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០៨, C22/5/15, ERN 00282674-00282679, កថាខណ្ឌទី១២-១៥។

និងវិធាន៣២ នៃវិធានផ្ទៃក្នុងនោះក្តីក៏ "របាយការណ៍ខ្លី"("សេចក្តីសង្ខេប") របស់គាត់ គឺមិនអាចមានលក្ខណៈសម្បត្តិជា "របាយការណ៍របស់អ្នកជំនាញឯកទេស"បានដែរ ។ "សេចក្តីសង្ខេប" គឺមិនបានផ្អែកលើព័ត៌មានពីដើមដំបូងគេណាមួយទេ។ ប៉ុន្តែគឺគ្រាន់តែជាការធ្វើសេចក្តីសង្ខេបមួយនៃរបាយការណ៍វេជ្ជសាស្ត្រទាំងអស់ដែលដើមបណ្តឹងឧទ្ធរណ៍បានផ្តល់ទៅឱ្យលោកវេជ្ជបណ្ឌិត Falke តែប៉ុណ្ណោះ ដែលមិនមានលក្ខណៈពេញលេញនិងមិនមានធ្វើសេចក្តីសន្និដ្ឋាន។ ។ ឧទាហរណ៍ដូចជា សេចក្តីសង្ខេបនោះ មិនបានឆ្លើយតបទៅនឹងសំនួរចំនួនបួន ដែលបានចោទសួរទៅលោកវេជ្ជបណ្ឌិត Falke ដូចខាងក្រោមនេះ៖

"i. តើធ្វើដូចម្តេចដើម្បីឱ្យយើងអាចបង្ហាញសក្ខីកម្មឱ្យឃើញថា តើលោក អៀង សារី មានសុខភាពរឹងមាំអាចនឹងធ្វើការឃុំខ្លួនបានដែរ ឬទេ?

ii. តើលោកអៀង សារី មានសុខភាពរឹងមាំអាចនឹងចូលរួមនៅក្នុងសវនាការបានដែរ ឬទេ?

iii. តើលោកអៀង សារីមានសុខភាពរឹងមាំអាចចូលរួមនៅក្នុងការការពារក្តីរបស់គាត់ផ្ទាល់បានដែរ ឬទេ?

iv. តើមានការធ្វើតេស្តសាកល្បងណាបន្ថែមទៀតដើម្បីធ្វើរោគវិនិច្ឆ័យដើម្បីកំណត់អំពីស្ថានភាពសុខភាពបច្ចុប្បន្នខាងផ្លូវកាយ និងខាងស្មារតី និងពីសមត្ថភាពរបស់លោកអៀង សារីដែរ ឬទេ?"[25]

១៩. សេចក្តីសង្ខេបចំនួនពីរទំព័ររបស់លោកវេជ្ជបណ្ឌិត Falke ដែលនៅក្នុងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាថា មិនមានការផ្តល់នូវកោសលវិច័យណាមួយ ហើយក៏មិនបានជួយដល់តុលាការក្នុងការធ្វើឱ្យយល់កាន់តែច្បាស់ល្អថែមទៀតលើបញ្ហាណាមួយ ដែលបានលេចឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍នេះទេ ។ សេចក្តីសង្ខេបនេះខំព្យាយាមធ្វើសង្ខេបរបស់គាត់នូវយោបល់របស់អ្នកជំនាញនានាដែលមានគុណវុឌ្ឍិខ្ពស់ជាងលោកវេជ្ជបណ្ឌិត Falke ដែលគាត់គ្រាន់តែជាគ្រូពេទ្យប្រកបវិជ្ជាជីវៈទូទៅមួយរូបប៉ុណ្ណោះ។ ក្នុងការតាក់តែងនូវសេចក្តី

---

[25] ពាក្យសុំទី១, ឧបសម្ព័ន្ធ ខ, របាយការណ៍របស់លោកវេជ្ជបណ្ឌិត Paulus Falke, ទំព័រ១។

00288277



សង្ខេបរបស់ខ្លួននេះ គឺលោកវេជ្ជបណ្ឌិត Falke ខំស្វែងរកដើម្បីធ្វើជា "អ្នកជំនាញមួយរូបពីលើអ្នកជំនាញទាំងឡាយ" ដែលមិនមែនជាអ្នកជំនាញដូចដែលនៅក្នុងវិធាន៣២ នៃវិធានផ្ទៃក្នុងបានកំណត់នោះទេ។ វិធាន៣២ នៃវិធានផ្ទៃក្នុង រំពឹងចង់ឱ្យបានអ្នកជំនាញឯកទេសជាអ្នកទទួលរ៉ាប់រងក្នុងការ "ពិនិត្យលើផ្នែកវេជ្ជសាស្ត្រ ផ្នែករោគវិកលវិទ្យា ឬផ្នែកចិត្តសាស្ត្រណាមួយ"របស់ចុងចោទ ហើយមិនមែនគ្រាន់តែដើម្បីឱ្យធ្វើសង្ខេប ឬផ្តល់មតិទៅលើរបាយការណ៍របស់អ្នកជំនាញទាំងឡាយដែលមានគុណវុឌ្ឍិខ្ពស់ជាងខ្លួន ដែលតុលាការនេះបានទទួលរួចហើយនោះទេ។

២០. សេចក្តីសង្ខេបរបស់លោកវេជ្ជបណ្ឌិត Falke នឹងមិនអាចជួយអ្វីតទៅទៀតបានទេ ដោយសារបញ្ហាដែលក្នុងសេចក្តីសង្ខេបនេះបានពោលអះអាងថា នឹងធ្វើការផ្តល់យោបល់ទៅតាមអ្វីដែលសហចៅក្រមស៊ើបអង្កេតបានស្នើប្រគល់ភារកិច្ចរួចហើយទៅឱ្យអ្នកជំនាញដែលមានគុណវុឌ្ឍិខ្ពស់ជាងនេះជាអ្នកធ្វើ ហើយរបាយការណ៍របស់អ្នកជំនាញទាំងនោះត្រូវបានទទួលមករួចហើយ។ ម្យ៉ាងទៀត របាយការណ៍បន្ថែមទៀតនឹងត្រូវបានទទួលដោយផ្អែកតាមមូលដ្ឋានដែលបានកំណត់ ក្នុងពេលខាងមុខ។ លក្ខខណ្ឌកំណត់អំពីការងារដែលបានផ្តល់ដោយសហចៅក្រមស៊ើបអង្កេតដល់អ្នកជំនាញរបស់ខ្លួនគឺមានលក្ខណៈល្អិតល្អន់ ឧទាហរណ៍ នៅក្នុងដីកាសម្រេចចាត់តាំងអ្នកជំនាញ ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៨ របស់ខ្លួនលក្ខខណ្ឌរបស់អ្នកជំនាញគឺមាន៖

i. "តើការពិនិត្យទៅលើជនជាប់ឃុំមានបង្ហាញឱ្យឃើញអំពីរោគសាស្ត្រជាក់លាក់ណាមួយ ឬទេ? បើសិនជាមានបង្ហាញនោះ សូមឱ្យរៀបរាប់និងចង្អុលបង្ហាញថា តើរោគសាស្ត្រនេះទាក់ទងទៅនឹងស្ថានភាពវេជ្ជសាស្ត្រអ្វីខ្លះ?

ii. សូមបញ្ជាក់មើល ថាតើជម្ងឺទាំងនេះមានតម្រូវឱ្យធ្វើការព្យាបាល ឬការថែទាំជាពិសេសដែរឬទេ? ឬមួយក៏ក្នុងនោះមានការចង្អុលប្រាប់ណាមួយផ្ទុយពីនេះ? ជាការច្បាស់លាស់ជាងនេះទៅទៀតនោះ គឺតើស្ថានភាពវេជ្ជសាស្ត្រតម្រូវឱ្យមានវិធានការ

ជាក់លាក់ផ្សេងៗដែរឬទេ? គឺពាក់ព័ន្ធទៅនឹងលក្ខខណ្ឌនៃការឃុំខ្លួនរបស់ជនជាប់ឃុំផង ហើយនិងទៅនឹងការចូលរួមរបស់គាត់នៅក្នុងការស៊ើបសួររបស់តុលាការផង។

iii. តើនៅក្នុងការពិនិត្យផ្នែកវេជ្ជសាស្ត្រទាំងនេះមានត្រូវការអ្នកជំនាញឯកទេសផ្សេងទៀតដែរ ឬទេ? បើសិនជាត្រូវការនោះ តើអ្នកជំនាញផ្នែកអ្វី?

iv. បើសិនជាចាំបាច់ សូមផ្តល់នូវវិនិច្ឆ័យទុកជាមុនមួយអំពីលទ្ធភាពដើម្បីធ្វើការកែប្រែ តើស្ថានភាពមានការថយចុះ ឬមួយក៏ល្អប្រសើរឡើង"[26]។

v. សូមផ្តល់នូវសេចក្តីសង្កេតផ្សេងៗទៀត ដែលមានប្រយោជន៍ស្តីពីសុខភាពរបស់ជនជាប់ឃុំ។

២១. សេចក្តីសង្ខេបរបស់លោកវេជ្ជបណ្ឌិត Falke គ្មានបានបន្ថែមអ្វីទាល់តែសោះ ទៅលើអ្វីដែលតុលាការនេះឬអ្នកជំនាញខាងវេជ្ជសាស្ត្រទាំងឡាយ ដែលត្រូវបានចាត់តាំងមិនបានដឹងទេ។ សេចក្តីសង្ខេបមិនបានផ្តល់នូវកោសលវិច័យថ្មីណាមួយនោះទេ លើកលែងតែនិយាយអំពីការដែលលោកវេជ្ជបណ្ឌិត Falke មិនមានលទ្ធភាពក្នុងការឈានទៅដល់ការធ្វើសេចក្តីសន្និដ្ឋានតែប៉ុណ្ណោះ ដោយសារតែគ្មានការធ្វើតេស្តពិសោធន៍មួយចំនួនដែល-ផ្អែកតាមយោបល់គាត់ថា-ចាំបាច់គឺត្រូវធ្វើទៅលើដើមបណ្តឹងឧទ្ធរណ៍។ ទោះបីជាការធ្វើតេស្តពិសោធន៍ទាំងនេះត្រូវបានធ្វើឡើងក្តី ក៏លោកវេជ្ជបណ្ឌិត Falke នឹងមិនមែនជាអ្នកដែលត្រូវធ្វើសេចក្តីអធិប្បាយផ្តល់មតិទៅលើ(លទ្ធផលនៃ)ការធ្វើតេស្តពិសោធន៍ទាំងនេះ ស្របតាមការចាំបាច់ដែលតម្រូវឱ្យអ្នកជំនាញឯកទេសជាអ្នកធ្វើការវាយតម្លៃដែរ ដែលលោកវេជ្ជបណ្ឌិត Falke មិនមែនជាអ្នកជំនាញដូចនោះផង។

២២. អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញា សូមស្នើឱ្យ អង្គបុរេជំនុំជម្រះ បដិសេធចោលនូវសេចក្តីសង្ខេបខាងលើរបស់លោកវេជ្ជបណ្ឌិត Falke ដោយសារតែសេចក្តីសង្ខេបនោះបំពេញ

---

[26] *ករណីរឿងរបស់អៀង សារី*, ចម្លើយតបរបស់សហព្រះរាជអាជ្ញា ដីកាសម្រេចចាត់តាំងអ្នកជំនាញ, សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, ចុះថ្ងៃទី២១ កុម្ភៈ ២០០៨, ERN 00164556-00164557, D76, ទំព័រ២។

មិនបានគ្រប់តាមលក្ខខណ្ឌតម្រូវនានាស្តីពីរបាយការណ៍របស់អ្នកជំនាញ ដូចដែលមានចែងនៅក្នុងវិធាន៣១ និងវិធាន៣២ នៃវិធានផ្ទៃក្នុង។

## *ពាក្យសុំគឺជាការខាតបង់ផ្សេងៗដោយឥតប្រយោជន៍ ហើយនឹងធ្វើឱ្យខូចខាតដល់ការសន្សំសំចៃរបស់តុលាការ*

២៣. ដូចបានលើកឡើងខាងលើ ពាក្យសុំបច្ចុប្បន្ននេះត្រូវបានដាក់ជាបន្ថែមពីលើសំណើចម្រុះមួយដែលបានដាក់ហើយដែលត្រូវបានបដិសេធចោលនៅក្នុងពេលថ្មីៗបំផុតនេះ នៅក្នុងដំណើរការនៃនីតិវិធីតែមួយដដែល ដែលក្នុងនោះ ដើមបណ្តឹងឧទ្ធរណ៍បានស្នើសុំឱ្យធ្វើដីកាកោះអញ្ជើញវេជ្ជបណ្ឌិត និងអ្នកជំនាញស្ទើរតែទាំងអស់ដែលមានចំនួនដ៏ច្រើនដែលធ្លាប់បានពិនិត្យព្យាបាលជម្ងឺឱ្យគាត់នៅក្នុងរយៈពេលឃុំខ្លួនគាត់ដប់ប្រាំខែកន្លងមកនេះ។ សហព្រះរាជអាជ្ញា បានច្រានចោលនូវសំណើចម្រុះនេះ ដោយសារតែមូលហេតុយឺតពេលពេក មិនច្បាស់លាស់ ទូលំទូលាយហួសពេក និងមិនមានការចង្អុលបង្ហាញភស្តុតាងខាងអង្គហេតុ និងខាងអង្គច្បាប់[27]។ ក្នុងរយៈពេលប៉ុន្មានថ្ងៃនៃការបដិសេធលើសំណើចម្រុះ និងការបដិសេធលើពាក្យសុំទីមួយដែលស្នើឱ្យចេញដីកាកោះអញ្ជើញលោកវេជ្ជបណ្ឌិត Falke ឱ្យមកធ្វើជា "សាក្សី" នោះដើមបណ្តឹងឧទ្ធរណ៍បានដាក់ពាក្យសុំទីពីរ ដែលស្នើសុំឱ្យចេញដីកាកោះអញ្ជើញលោកវេជ្ជបណ្ឌិត Falke ជាគ្រូពេទ្យដែលជាអ្នកដែលប្រកបវិជ្ជាជីវៈទូទៅ - ដែលមិនមានគុណវឌ្ឍិជា"អ្នកជំនាញឯកទេស"មួយរូប - ដើម្បីធ្វើការវាយតម្លៃនិងពន្យល់អំពីរបាយការណ៍របស់អ្នកជំនាញនានាដែលមានគុណវុឌ្ឍិខ្ពស់ជាងគាត់និងដែលមានចំណេះដឹងខ្ពស់ជាងគាត់និងដែលអាចមានសិទ្ធិជួបប្រាស្រ័យជាមួយដើមបណ្តឹងឧទ្ធរណ៍ដោយផ្ទាល់ និងអាចបើកមើលឯកសារពេទ្យរបស់គាត់បាន។ ហេតុដូចនេះ បណ្តឹងឧទ្ធរណ៍នេះនឹងក្លាយទៅជាការចំណាយពេលវេលា និងធនធានខ្ជះខ្ជាយឥតប្រយោជន៍ ហើយនឹងធ្វើឱ្យខូចទៅដល់ការសន្សំសំចៃរបស់តុលាការទៀតផង។

---

[27] *ករណីរឿងរបស់ អៀង សារី,* ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ អៀង សារី ដែលស្នើសុំឱ្យពិនិត្យអ្នកជំនាញវេជ្ជសាស្ត្រ នៅក្នុងពេលសវនាការផ្ទាល់មាត់លើបណ្តឹងឧទ្ធរណ៍ស្តីពីការបន្តចិរវេលានៃការឃុំខ្លួន, សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ១៧) ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០៩, ERN 00282674-00282667, C22/5/15 ។

C22/5/30

*សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អបជ-១៧)*

## ៣. សេចក្តីសន្និដ្ឋាន

២៤. សហព្រះរាជអាជ្ញា សូមស្នើដល់អង្គបុរេជំនុំជម្រះ ឲ្យបដិសេធចោលនូវពាក្យសុំទីពីរ នេះ។

ធ្វើនៅភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា
នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៩

**សហព្រះរាជអាជ្ញា**

**លោកស្រី ជា លាង** **លោក** Robert PETIT